ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំឆ្នាំ២០២០ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងឆ្នាំ២០២០នេះ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបានចំនួន ២ ៧៩០ ៨២៩ហ.ត ស្មើនឹង ១០៧,៨៣% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត។ គ្រោះទឹកជំនន់ទឹកភ្លៀងបានបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរនៅតាមបណ្តាខេត្តភាគពាយ័ព្យនៃប្រទេស។ វិធានការជួយសង្គ្រោះបន្ទាន់ត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិកររងផលប៉ះពាល់។ រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងឆ្នាំ២០២០នេះ គឺបានរៀបចំកិច្ចប្រជុំសំខាន់ៗ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២០ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងឆ្នាំ២០២០នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះ

#### ១.១ លទ្ធផលបញ្ចប់ផលិតកម្មដំណាំស្រូវរដូវវស្សា

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ មានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៨៤១ ៦០៣ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ២៦ ៤០៥ហ.ត ស្មើនឹង០,៩៣% និងដោយគ្រឿងយន្តមានចំនួន ២ ៨១៥ ១៩៨ហ.ត ស្មើនឹង៩៩,០៧%
- ផ្ទៃដីសាបសម្រេចបានចំនួន ១៥ ៧៨២ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៧៩០ ៨២៩ហ.ត ស្មើនឹង១០៧,៨៣% នៃផែនការចំនួន ២ ៥៨៨ ១៣០ហ.ត លើសឆ្នាំមុនចំនួន ៥៩ ៤៩១ហ.ត។

#### ១.២ ការប្រមូលផលស្រូវរដូវវស្សា

ការប្រមូលផលស្រូវរដូវវស្សាសម្រេចបានចំនួន ២ ៥៩០ ៣៥២ហ.ត ទទួលបរិមាណផលសរុបចំនួន ៨ ២១៩ ៦៧៧តោន និងទទួលបានទិន្នផលគិតជាមធ្យម ៣,១៧៣តោន/ហ.ត។

#### ១.៣ ផលិតកម្មដំណាំស្រូវរដូវប្រាំង

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៤៩៧ ៣៧៤ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ២ ៣១៧ហ.ត ស្មើនឹង០,៤៧% និងដោយគ្រឿងយន្តចំនួន ៤៩៥ ០៥៧ហ.ត ស្មើនឹង៩៩,៥៣%
- ផ្ទៃដីសាបសម្រេចបានចំនួន ២៥ហ.ត

○ ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៤៩៥ ៩០៧ហ.ត ស្មើនឹង ១០៧,៩៩% នៃផែនការចំនួន ៤៥៩ ២០០ហ.ត តិចជាងឆ្នាំមុន ៤៧ ៧៩២ហ.ត។

### ១.៤ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវប្រាំង

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ២៤ ២៤៩ហ.ត ស្មើនឹង៦៤,៩៩% នៃផែនការចំនួន ៣៧ ៣១២ហ.ត តិចជាងឆ្នាំមុន ២ ៨៣៣ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៥៣ ៣៧២ហ.ត ស្មើនឹង៦២,៩៦% នៃផែនការចំនួន ៨៤ ៧៧០ហ.ត តិចជាងឆ្នាំមុន ២១៨ហ.ត។

### ១.៥ ការនាំចេញផលិតផលកសិកម្ម

#### ១.៥.១ ការនាំចេញអង្ករ

បរិមាណនាំចេញអង្ករបានចំនួន ៦៩០ ៨២៩តោន កើនឡើងចំនួន ៧០ ៧២៣តោន (+១១,៤%) ច្រើនជាងបរិមាណនាំចេញក្នុងឆ្នាំ២០១៩ ដែលមានចំនួន ៦២០ ១០៦តោន។ ការនាំចេញទៅកាន់ទិសដៅចំនួន ៦០ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ចំនួន ២៨៩ ៤៣៩តោន ប្រទេសបារាំងឈរលំដាប់ទី២ចំនួន ៨១ ៣៦៦តោន ប្រទេសហ្គាបុងឈរលំដាប់ទី៣ចំនួន ៤៩ ៣៩៤តោន ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤ចំនួន ៤២ ៧៧៤តោន ប្រទេសអូស្ត្រាលីឈរលំដាប់ទី៥ចំនួន ២៩ ៣០៥តោន ប្រទេសណេដឺឡែនឈរលំដាប់ទី៦ចំនួន ២៥ ៨២៦តោន ប្រទេសប្រ៊ុយណេឈរលំដាប់ទី៧ចំនួន ១៥ ៨១៣តោន ប្រទេសអង់គ្លេសឈរលំដាប់ទី៨ចំនួន ១៤ ៧២៤តោន ប្រទេសប៉ូឡូញឈរលំដាប់ទី៩ចំនួន ១២ ៨៦០តោន និងប្រទេសវៀតណាមឈរលំដាប់ទី១០ចំនួន ១២ ៨៣៦តោន ហើយបច្ចុប្បន្នក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៧៦ក្រុមហ៊ុន។

#### ១.៥.២ ការនាំចេញកសិផលផ្សេងៗ

បរិមាណនាំចេញផ្លែចេកស្រស់ចំនួន ៣៣៣ ១៤២តោន ទៅកាន់ប្រទេសចិន វៀតណាម ជប៉ុន និងប្រទេសសិង្ហបុរី។ ផ្លែស្វាយ-ស្រស់ចំនួន ៩៧ ៦២៧តោន ទៅកាន់ប្រទេសថៃ វៀតណាម បារាំង រុស្ស៊ី កូរ៉េ ហុងកុង និងប្រទេសសិង្ហបុរី។ គ្រាប់ពោតចំនួន ១៩៤ ៦២៥តោន ទៅកាន់ប្រទេសថៃ កូរ៉េ តៃវ៉ាន់ និងប្រទេសវៀតណាម។ គ្រាប់ស្វាយចន្ទីចំនួន ២១៨ ៩៨១តោន ទៅកាន់ប្រទេសវៀតណាម ជប៉ុន រុស្ស៊ី ចិន ហុងកុង ថៃ បារាំង កូរ៉េ តួគី បង់ក្លាដេស ម៉ាឡេស៊ី ហូឡង់ និងប្រទេសឡាវ។ ម្រេចចំនួន ៥ ០៧៩តោន ទៅកាន់ប្រទេសជប៉ុន ប៉ែលហ្ស៊ិក ហូឡង់ បារាំង អាល្លឺម៉ង់ ស្វីស វៀតណាម អាមេរិច រុស្ស៊ី អង់គ្លេស ឥណ្ឌា បេឡារូស កូរ៉េ ឆេក ណូវែហ្សេឡង់ អូស្ត្រាលី ថៃ តៃវ៉ាន់ ស៊ុយអ៊ែត សិង្ហបុរី កាណាដា កាហ្សាក់ស្ថាន់ ដាណឺម៉ាក អ៊ីស្រាអ៊ែល និងហុងកុង។ ម្ទេសស្រស់ចំនួន ៧០ ៥៤៦តោន ទៅកាន់ប្រទេសថៃ។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤០១ ៦៩៩ហ.ត ក្នុងនោះ ផ្ទៃដីចៀរជ័រមានចំនួន ២៨៩ ៨៣៧ហ.ត ស្មើនឹង៧២% និងផ្ទៃដីថែទាំមានចំនួន ១១១ ៨៦៣ហ.ត ស្មើនឹង២៨%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ២៩១ ៣២៧តោន បានកើនឡើងចំនួន ៥៣ ០៧៤តោន ស្មើនឹង២២% ធៀបឆ្នាំ២០១៩។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណបញ្ចេញលក់សម្រេចបានចំនួន ២៨៥ ៥៨៩តោន បានកើនឡើងចំនួន ៥១ ៨២០តោន ស្មើនឹង២២% ធៀបឆ្នាំ២០១៩។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃលក់មធ្យមក្នុងខែធ្នូ គឺ១ ៥១៤ដុល្លារ/តោន បានកើនឡើងចំនួន ៨១ដុល្លារ/តោន ស្មើនឹង៥,៧%ធៀបនឹងខែមុន និងកើនឡើងចំនួន ១៨៧ដុល្លារ/តោន ស្មើនឹង១៤% ធៀបខែធ្នូ ឆ្នាំ២០១៩

- តម្លៃលក់មធ្យមរយៈពេល១២ខែ គឺ១ ៣៤១ដុល្លារ/តោន បានកើនឡើងចំនួន ១២ដុល្លារ/តោន ស្មើនឹង០,៩% ធៀបឆ្នាំ២១០៩

- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការក្នុងខែធ្នូ គឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៥ ១៥០៛/គ.ក្រ ដល់ ៥ ៩៥០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ២៥០៛/គ.ក្រ ដល់ ២ ៩២៥៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការខារព្រៃឈើ

- បានទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០១៩ ចំនួន ២៧ ផ្ទាំង (LANDSAT8) ឆ្នាំ២០២០ ចំនួន ២២ ផ្ទាំង និង Sentinel2 ឆ្នាំ២០២០ ចំនួន ២០ ផ្ទាំង សម្រាប់ការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២០

- បានចុះពិនិត្យ និងផ្ទៀងផ្ទាត់តំបន់សក្តានុពលព្រៃសហគមន៍ចំនួន ៥កន្លែង ស្ថិតក្នុងខេត្តកំពង់ស្ពឺ ស្វាយរៀង និងខេត្តកំពត ដែលមានផ្ទៃដីសរុបទំហំ ១ ២៣៦,១៩ហ.ត

- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្ត និងយានយន្តជូនដល់ក្រុមហ៊ុនចំនួន ១៤ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ៤នាក់ ដែលមានរណារយន្តសរុបចំនួន ១៩៨គ្រឿង និងយានយន្តចំនួន ២០៨គ្រឿង

- បានផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ១១ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ២០នាក់។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- បានចុះអន្តរាគមន៍ទប់ស្កាត់ និងបង្រ្កាបការជួញដូរសត្វព្រៃចំនួន ៣លើក នៅខេត្តរតនគិរី មណ្ឌលគិរី និងខេត្តព្រះវិហារ ដោយរឹបអូសបានសត្វអណ្តើករស់ចំនួន ៨ក្បាល សត្វត្រកួតរស់ចំនួន ២ក្បាល និងដោះអន្ទាក់សត្វព្រៃចំនួន ១៥ខ្សែ

- បានចុះសិក្សាស្រាវជ្រាវ និងធ្វើការតាមដានវត្តមានសត្វព្រៃចំនួន ៦លើក នៅក្នុងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ និងសហគមន៍ព្រៃឈើក្នុងខេត្តរតនគីរី ក្រចេះ ព្រះវិហារ និងខេត្តកំពង់ស្ពឺ ដោយកត់ត្រាបានសត្វព្រៃចំនួន ១៥៥ប្រភេទ ក្នុងនោះមានថនិកសត្វចំនួន ៥១ប្រភេទ បក្សីចំនួន ៦៨ប្រភេទ និងឧរង្គសត្វចំនួន ៣៦ប្រភេទ

- បានចុះប្រមូលសំណាករុក្ខជាតិកេសរកូល (អ័រគីដេព្រៃ) ចំនួន ៤លើក នៅខេត្តពោធិ៍សាត់ ព្រះវិហារ និងខេត្តមណ្ឌលគិរី ដោយប្រមូលសំណាករុក្ខជាតិកេសរកូលចំនួន ១៩ប្រភេទ ស្មើនឹង ៣៥៣សំណាក និងបានយកមកថែរក្សា បន្សាំ ចិញ្ចឹម និងបណ្តុះនៅក្នុងសួនអ័រគីដេរដ្ឋបាលព្រៃឈើភ្នំពេញថ្មី

- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ១២៣ច្បាប់ ក្នុងនោះ ១០៨ច្បាប់ សម្រាប់ការថែរក្សាសត្វត្រចៀកកាំ និង ១៥ច្បាប់ សម្រាប់ការថែរក្សាសត្វព្រៃប្រភេទផ្សេងទៀត ដែលមាន ទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកោះកុង កំពត កំពង់ស្ពឺ កំពង់ធំ បាត់ដំបង ពោធិ៍សាត់ រតនគិរី កំពង់ចាម ត្បូងឃ្មុំ សៀមរាប ប៉ៃលិន បន្ទាយមានជ័យ និងខេត្តកណ្តាល។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន ៧មានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៨កន្លែង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានស្វាក្តាមសរុបចំនួន ៦៩ ២១៥ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ៤២ ៧៩២ក្បាល ដឹកជញ្ជូនក្នុងស្រុកចំនួន ៨ ៤៩០ក្បាល និងដឹកជញ្ជូនឆ្ពោះទៅកាន់មាត់ច្រកអន្តរជាតិសម្រាប់នាំចេញទៅក្រៅប្រទេសចំនួន ២២ ៥៩៤ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៦១៣ក្បាល(បក្សីចំនួន ៥៦ប្រភេទ ថនិកសត្វចំនួន ៤៥ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ១ ៧៦៤ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ៣៨០ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ១ ៣៩៦ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ៣០ នាក់ បានចុះល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ០៥ គឺ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់) បានរកឃើញលាមកចំនួន ៩០សំណាក ដានជើងចំនួន ២៣កន្លែង ឃើញក្រពើផ្ទាល់ចំនួន ៥៣ក្បាល រកឃើញសំបុកក្រពើភ្នំចំនួន ១មានពង ២២គ្រាប់ នៅបឹងវាលវែង អូរសោម ខេត្តពោធិ៍សាត់ និងស្រាវជ្រាវវត្តមានក្រពើភ្នំនៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ដោយរកឃើញស្នាមជើងក្រពើភ្នំចំនួន ៣កន្លែង

- បានជួសជុលផ្លូវដោយក្រាលក្រួសក្រហមសរុបប្រវែង ២៩គីឡូម៉ែត្រ និងកាប់ស្តារអនាម័យព្រៃទំហំ ៥៤ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- បានដឹកប្រឡាយការពារចម្ការឈើគ្រញូងនៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំ ប្រចាំឆ្នាំ២០២០ ប្រវែង ៨ ០០០ម៉ែត្រ សម្រេចតាមផែនការ

- ចុះធ្វើបច្ចុប្បន្នភាពលើការចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើនៅខេត្តមណ្ឌលគិរី រតនគិរី ក្រចេះ និងខេត្តស្ទឹងត្រែង

- បានដាំឈើជាចម្ការថ្មីលើផ្ទៃដីទំហំ ១៥០ហ.ត ក្នុងនោះស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំមានផ្ទៃដីទំហំ ១០០ហ.ត និងស្ថានីយដាំឈើម្សៅក្រដាស ហ៊ុន សែន មានក នៅខេត្តកំពង់ឆ្នាំងមានផ្ទៃដីទំហំ ៥០ហ.ត

- បានបណ្ដុះកូនឈើគ្រប់ប្រភេទសរុបចំនួន ៥៣៧ ៥៣៨ដើម (ខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ៣៦៨ ៨៣៨ដើម និងនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជនចំនួន ១៦៨ ៧០០ដើម) និង ចែកចាយកូនឈើចំនួន ៥២ ៩៣១៧ដើម (ខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ៣៦០ ៦១៧ដើម និងនាយកដ្ឋានអភិវឌ្ឍន៍ចម្ការព្រៃដាំ និងព្រៃឯកជនបានចំនួន ១៦៨ ៧០០ ដើម)។

**៣.៥ ការងារនីតិកម្ម និងវិវាទ**

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ១ ៤៣៥ករណី ដោយពិន័យអន្តរការណ៍ចំនួន ៥៧២ករណី និងបញ្ជូនទៅតុលាការចំនួន ៨៦៣ករណី។

**៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម**

- បានបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ស្ថិតក្នុង រាជធានី-ភ្នំពេញ ខេត្តតាកែវ ស្វាយរៀង រតនគិរី ព្រៃវែង កំពង់ធំ កណ្ដាល កំពង់ស្ពឺ កំពង់ចាម ត្បូងឃ្មុំ សៀមរាប ព្រះវិហារ កំពង់ឆ្នាំង និងខេត្តកំពត ស្មើនឹង ១៩កន្លែង

- បានបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើ និងឡធ្យូងចំនួន ១២ព្រមទាំងពន្យារសុពលភាពចំនួន ១២កន្លែង

- ផ្តល់គំរូលិខិតអនុញ្ញាតបង្កើតរោងសន្និធិប្រភេទតូចចំនួន ៥៣១សន្លឹក សិប្បកម្មចំនួន ២៥៣សន្លឹក និង លិខិតអនុញ្ញាតសន្និធិចំនួន ១៣៨សន្លឹក

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ១៣មានឈើកែច្នៃចំនួន ៥ ០១០ម៣ ប្រេងខ្យល់កាត់ជាកង់ៗចំនួន ១ ៥០០ស្នែរ កម្ទេចឈើចំនួន ៩ ០០០តោន ធ្យូងអាកាស្យាចំនួន ៤១តោន ឫស្សីកែច្នៃចំនួន ៤២តោន និងជ័រទឹកចំនួន ៤៧៦តោន

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន ៥មានឈើកែច្នៃចំនួន ២ ៧៥១ម៣ ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្ដុះបណ្ដាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្ដាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្ដារាជធានី-ខេត្តរៀងរាល់សប្ដាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្ងួនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

**៤.២ ការងារសុខភាពសត្វ**

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិត-ផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ១៨៣ករណី។ រាជធានី-ខេត្តចំនួន ២៥បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ១៦៥ ៣៥៧លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស**

- ចុះប្រជុំណែនាំស្តីពីបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វនៅតាមបណ្ដាខេត្តចំនួន៦
- ចុះបណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមសត្វនិងបច្ចេកទេសដាំដំណាំចំណីសត្វនៅតាមបណ្ដាខេត្តចំនួន៥
- ចុះប្រជុំណែនាំពីជំងឺផ្ដាសាយបក្សីជាមួយកសិករ និងអ្នកពាក់ព័ន្ធនៅតាមបណ្ដាខេត្តចំនួន៨
- ចុះផ្សព្វផ្សាយ បច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្ដាខេត្តចំនួន១៨
- ចុះផ្សព្វផ្សាយជំងឺប៉េស្តជ្រូកអាហ្វ្រិកនៅតាមបណ្ដាខេត្តចំនួន៣។

- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាលើសេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វទីកន្លែងកែច្នៃបឋមផលិតផលសត្វ

- កំពុងប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

- កំពុងប្រជុំផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត វិញ្ញាបនបត្រនិង បទដ្ឋានបច្ចេកទេសបសុពេទ្យាបាលសម្រាប់ចរាចរណ៍សត្វ និងផលិតផលសត្វ

- កំពុងប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីចុះបញ្ជី ការគ្រប់គ្រងសហគមន៍សុខភាពសត្វ និងផលិត-កម្មសត្វ

- ចុះប្រជុំផ្សព្វផ្សាយកម្រងលិខិតបទដ្ឋានគតិយុត្តវិស័យសុខភាពសត្វ និងផលិតកម្មសត្វនៅតាមបណ្តាខេត្ត ចំនួន១២ និងចុះពិនិត្យ និងតាមដានការអនុវត្តច្បាប់លើវិស័យសុខភាពសត្វនិងផលិតកម្មសត្វនៅខេត្តកែប១លើក។

**៤.៣ ការងារស្រាវជ្រាវ**

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០២ក្បាល។ ចំណែកស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនត្រូវបានបិទទាំងស្រុងនៅថ្ងៃទី១៥ មេសា ឆ្នាំ២០២០ ដោយសារមានការឆ្លងរាលដាលនៃជំងឺប៉េស្តជ្រូកអាហ្វ្រិក
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបបានចំនួន ១៨ ៤៥២វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៥ ផ្នែកជលផល

**៥.១ អាជីវកម្មនេសាទ**

៥.១.១ នេសាទទឹកសាប

- ជាយត្រីអនុវត្តបានចំនួន ៩ ៩០០តោន ស្មើនឹង៨២,៥០% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបឆ្នាំ២០១៩ ថយចុះចំនួន ៤ ៤២០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ២៦៨ ០០០តោន ស្មើនឹង៧៧,៦៨% នៃផែនការចំនួន ៣៤៥ ០០០តោន ប្រៀបធៀបឆ្នាំ២០១៩ ថយចុះចំនួន ៥៨ ៥០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ១៣៥ ៣០០តោន ស្មើនឹង៩៣,៣១% នៃផែនការចំនួន ១៤៥ ០០០តោន ប្រៀបធៀបឆ្នាំ២០១៩ ថយចុះចំនួន ២ ៧៣០តោន។

៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ១២២ ៧០០តោន ស្មើនឹង១១១,៥៥% នៃផែនការចំនួន ១១០ ០០០តោន ប្រៀបធៀបឆ្នាំ២០១៩ កើនឡើងចំនួន ៤៥០តោន។

**៥.២ វារីវប្បកម្ម**

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ៤០០ ៤០០តោន ស្មើនឹង១១១,២២% នៃផែនការចំនួន ៣៦០ ០០០តោន ប្រៀបធៀបឆ្នាំ២០១៩ កើនឡើងចំនួន ៩២ ៩៩២តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ៣១៣ ១០០ក្បាល ស្មើនឹង១០៤,៣៧% នៃផែនការចំនួន ៣០០ ០០០ក្បាល ប្រៀបធៀបឆ្នាំ២០១៩ ថយចុះចំនួន ៩៩ ៧១១ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ២៣៥ ០០០ ០០០កូន ស្មើនឹង៩៧,៩២% នៃផែនការចំនួន ២៤០ ០០០ ០០០កូន ប្រៀបធៀបឆ្នាំ២០១៩ កើនឡើងចំនួនប្រមាណ ១៣ ០០០ ០០០កូន។

**៥.៣ ការកែច្នៃផលនេសាទ**

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៦២ ០០០តោន ស្មើនឹង៧៥,៦១% នៃផែនការចំនួន ៨២ ០០០តោន ប្រៀបធៀបឆ្នាំ២០១៩ ថយចុះចំនួន ១០ ០៧៥តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ១១ ៤០០តោន ស្មើនឹង១២៦,៦៧% នៃផែនការចំនួន ៩ ០០០តោន ប្រៀបធៀបឆ្នាំ២០១៩ កើនឡើងចំនួន ៤ ២៩៥តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៥៣ ០០០ ០០០លីត្រ ស្មើនឹង៩៦,៣៦% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបឆ្នាំ២០១៩ ថយចុះចំនួន ១ ០០០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ២ ៦៨៧ករណី ប្រៀបធៀបឆ្នាំ២០១៩ ថយចុះចំនួន ៤១៤ករណី ក្នុងនោះ បទល្មើសទឹកសាបចំនួន ២ ៤៧៩ករណី និងសមុទ្រចំនួន ២០៨ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ១ ៩៤៥តោន ស្មើនឹង១២,៩៧% នៃផែនការចំនួន ១៥ ០០០តោន ប្រៀបធៀបឆ្នាំ២០១៩ ថយចុះចំនួន ៧ ២៤៥តោន

- ផលនេសាទកែច្នៃនាំចេញចំនួន ២៣៤តោន ស្មើនឹង៤,៦៨% នៃផែនការចំនួន ៥ ០០០តោន ប្រៀបធៀបឆ្នាំ២០១៩ ថយចុះចំនួន ៤ ៦៧៦តោន។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងតាមបណ្តាអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ២៥លើក

- ចុះពិនិត្យ និងប្រជុំពិភាក្សាជាមួយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធពីបញ្ហាគ្រប់-គ្រងវិស័យជលផល និងព្រៃកោងកាងនៅខេត្តកែប

- ចុះត្រួតពិនិត្យ និងប្រជុំពិភាក្សាជាមួយថ្នាក់ដឹកនាំមន្ទីរលើការងារដឹកនាំ គ្រប់គ្រង និងជំរុញការកែលម្អចំណុចខ្វះខាតរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរី មណ្ឌលគិរី កោះកុង ព្រះសីហនុ កំពង់ធំ ប៉ៃលិន បាត់ដំបង ព្រះវិហារ សៀមរាប ស្ទឹងត្រែង ក្រចេះ កែប កំពត កំពង់ចាម ស្វាយរៀង ត្បូងឃ្មុំ និងខេត្តកំពង់ស្ពឺ

- បានទទួលពាក្យបណ្តឹងចំនួន ៦ករណី

- បានស្រាវជ្រាវព័ត៌មានតាមបណ្តាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៨៥៥ករណី

- ការចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ៧៨លើក

- បានបើកវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ច។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ៨ ៦១០ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ៣ ៥១៧ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣ ៣៥៥ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១ ៧៣៨ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១១ ២៨០ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៥០៤ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ២៣៣ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៥ ៨៥០នាក់ (ស្រី១ ៤២០នាក់ ស្មើនឹង២៤,២៧%) រួមមាន៖

  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៩២០នាក់ (ស្រី៨២៤នាក់ ស្មើនឹង២៨,២១%)
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩៣០នាក់ (ស្រី៥៩៦នាក់ ស្មើនឹង២០,៣៤%)

- បានរៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន២៧នាក់ (ស្រី៤នាក់) ក្នុងនោះ ដោយសុំលាឈប់ពីការងារចំនួន ៧នាក់ និងដោយមរណភាពមានចំនួន ១៩នាក់ និងដោយបោះបង់ចោលការងារចំនួន ១នាក់

- បានរៀបចំប្រកាសផ្ទេរមន្ត្រីរាជការផ្ទៃក្នុងក្រសួងចំនួន ៩២នាក់ (ស្រី២០នាក់) និងផ្ទេរមន្ត្រីរាជការទៅក្រៅក្រសួងចំនួន ៩នាក់

- បានរៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ៩៥នាក់ (ស្រី៦៤នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកព្យាបាលជំងឺចំនួន ១០នាក់ ច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ៤១នាក់ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ៣៩នាក់ ច្បាប់ឈប់សម្រាកមានធុរៈផ្ទាល់ខ្លួនចំនួន ២នាក់ និងច្បាប់ឈប់សម្រាករយៈពេលខ្លីចំនួន ៣នាក់

- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ៤៥នាក់ (ស្រី១៤នាក់)

- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យចូលបម្រើការងារវិញចំនួន ៣៣នាក់ (ស្រី៣នាក់)

- បានរៀបចំប្រកាសដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ចំនួន ២៣នាក់ (ស្រី១៣នាក់) និង ដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍មុនអាយុចំនួន ៣៧នាក់ (ស្រី៩នាក់)

- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ២ ៧៣៤នាក់ (ស្រី៦២៦នាក់) ក្នុងនោះ៖

  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ២ ៣៤១នាក់ (ស្រី៥៣៤នាក់)

  + ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ៣៩៣នាក់ (ស្រី៩២នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- បានរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មឆ្នាំ២០១៩-២០២៣ សម្រាប់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយសហការជាមួយកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ

- បានចុះបង្ហាញពីគោលការណ៍នាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មឆ្នាំ២០១៩-២០២៣ ដល់គ្រប់ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានអនុញ្ញាតជាគោលការណ៍ឱ្យបញ្ចេញស្រូវពូជចាស់អន់គុណភាពដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់

- បានចុះពិនិត្យសន្និធិស្រូវពូជចំនួន ៣ខេត្ត គឺមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាល កំពង់ឆ្នាំង និងខេត្តតាកែវ

- បានចូលរួមធ្វើរបាយការណ៍ស្តីពីការចុះពិនិត្យស្ថានភាពប្រឈម និងទិសដៅអនុវត្តបន្តរបស់គម្រោងសម្បទានដីសេដ្ឋកិច្ចដោយសហការជាមួយរដ្ឋបាលខេត្ត និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ មណ្ឌលគិរី និងខេត្តកំពង់ស្ពឺ

- បានពិនិត្យតាមដានការងារបង្កបង្កើនផលស្រូវស្រាលឆ្នាំ២០២០

- បានចុះស្រង់ទិន្នន័យតម្លៃទីផ្សារកសិផលទូទាំង២៥ រាជធានី-ខេត្ត

- បានចូលរួមចុះពិនិត្យ តាមដាន និងវាយតម្លៃវឌ្ឍនភាពរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៩ ចំនួន៥លើក ស្មើនឹង៥ខេត្ត គឺខេត្តមណ្ឌលគិរី ត្បូងឃ្មុំ ស្ទឹងត្រែង ស្វាយរៀង និងខេត្តកំពង់ចាម។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានអនុវត្តប្រមូលចំណូលនូវទឹកប្រាក់សរុបមានចំនួន៤៨ ០៨២,២លានរៀល ស្មើនឹង១១៦% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ

- បានអនុវត្តចំណាយសរុបចំនួន១២៥ ០៧៣,៦លានរៀល ស្មើនឹង៧៤% ធៀបនឹងច្បាប់ហិរញ្ញវត្ថុ និងស្មើនឹង ៨៦% ធៀបនឹងឥណទានកែតម្រូវ

- ចំនួនគណនីធនាគារមានការប្រែប្រួលដោយក្នុងឆ្នាំ២០១៩ មាន២៨គណនី និងឆ្នាំ២០២០មានចំនួន៣៩គណនី កើនឡើង១១គណនី

- ទទួលបង្កាន់ដៃបង់ប្រាក់កក់ពីក្រុមហ៊ុនចំនួន១

- ចុះប្រមូលថ្លៃសម្បទានដីសេដ្ឋកិច្ចសរុបចំនួន ៦៧ក្រុមហ៊ុន

- ទទួលចំណូលពីការបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន ៣៩ក្រុមហ៊ុន

- បានចុះពិនិត្យ និងវាយតម្លៃទ្រព្យសម្បត្តិរបស់គម្រោងកម្មវិធីជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្នអនុវិស័យជលផល និងផលិតកម្មសត្វរបស់ LiveStock Sub-sector Component ក្រោមជំនួយឥតសំណងរបស់សហភាពអឺរ៉ុបដែលបានបញ្ចប់ និងត្រូវប្រគល់ជូនមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ ព្រះសីហនុ កោះកុង មណ្ឌលគិរី កំពង់ចាម ក្រចេះ ស្ទឹងត្រែង កំពង់ធំ សៀមរាប និងខេត្តព្រះវិហារ

- បានរៀបចំសំណើសុំនាំចេញវត្ថុវិភាគជំងឺផ្តាសាយបក្សី និងជំងឺអុតក្តាមទៅវិភាគនៅមន្ទីរពេទ្យចត្តាឡីស័កសត្វ និងរុក្ខជាតិ (APQA) នៃសាធារណរដ្ឋកូរ៉េ

- បានពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីគណនេយ្យឆ្នាំ២០១៩នៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៩ (ឆ្នាំគោល) និងធ្វើការគ្រប់គ្រង បែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខាបច្ចេកទេស ថែទាំ និងជួសជុល

- បានរៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងឆ្នាំ២០២១-២០២៣ ផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ ផែនការថវិកាឆ្នាំ២០២១ ផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២១ និងផែនការរដ្ឋ-ទេយ្យបុរេប្រទានឆ្នាំ២០២១

- រៀចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសទី១ M2 ប្រចាំឆ្នាំ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ

- បានចុះធ្វើសវនកម្មចំនួន ៣៨សវនដ្ឋាន ស្មើនឹង៧៣,០៧% នៃផែនការ៥២សវនដ្ឋាន រកឃើញលទ្ធផលសវនកម្ម និងផ្តល់អនុសាសន៍សម្រាប់សវនដ្ឋានកែលម្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងចំនួន ១៩៦អនុសាសន៍ និងការអនុវត្តអនុសាសន៍គ្រាមុនរបស់សវនដ្ឋានសម្រេចបានចំនួន ៥៦,១៤% នៃផែនការចំនួន ៥២%។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានទទួលជួបភ្ញៀវស្ថានទូត អង្គការអន្តរជាតិ វិស័យឯកជន និងផ្សេងៗចំនួន ២១លើក

- បានចូលរួមកិច្ចប្រជុំ សិក្ខាសាលា ទស្សនកិច្ច និងសន្និសីទចំនួន ២១លើក

- បានចូលរួមសិក្ខាសាលាចំនួន ៥លើក វគ្គបណ្តុះបណ្តាលចំនួន ១០លើក ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី និងចូលរួមសិក្ខាសាលាចំនួន ១លើក វគ្គបណ្តុះបណ្តាលចំនួន ១លើក ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស

- បានសម្របសម្រួលរៀបចំកិច្ចប្រជុំតាមប្រព័ន្ធវីដេអូពីចម្ងាយចំនួន ២០លើក កិច្ចប្រជុំដោយផ្ទាល់ចំនួន ៨លើក ទិវាចំនួន ២លើក និងវគ្គបណ្តុះបណ្តាលចំនួន ៥លើកលើការងារក្នុងប្រទេស

- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយប្រទេសចិន ស្តីពី Technical Cooperation and Join Research on Integrated Water Resource Management and Development in Cambodia

- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយប្រទេសកូរ៉េ ស្តីពីគម្រោងហិរញ្ញប្បទានទៅរដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ សម្រាប់សារពើពន្ធឆ្នាំ ២០២២ ចំនួន ៧គម្រោង

- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយ Yamato Green ប្រទេសជប៉ុន ស្តីពី Safe Vegetable Development for Domestic Market and Export

- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយប្រទេស Hungary ស្តីពី Cooperation in the Field of Agriculture

- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយ Dana Asia ស្តីពីមជ្ឈមណ្ឌលខ្មែរ-ជប៉ុនបណ្តុះបណ្តាលចិញ្ចឹមមាន់

- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយអង្គការ FIDR ស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅខេត្តកំពង់ឆ្នាំង

- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយអង្គការ ADDA ស្តីពីគម្រោងពង្រឹងសមត្ថភាពសហគមន៍កសិកម្ម និងសង្គមស៊ីវិលនៅខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ

- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយ FAO ស្តីពី ១.ការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបច្ចេកទេសផ្តោតលើអាហារមានសុវត្ថិភាពតាមរយៈការអនុវត្តវិធានការសុវត្ថិភាពអាហារ និងការផ្តល់លិខិតបញ្ជាក់កសិផលនៅកម្ពុជា ២.ការពិនិត្យ ការធ្វើផែនការ និងកិច្ចពិគ្រោះយោបល់កម្រិតគោលនយោបាយសម្រាប់វិស័យកសិកម្ម និងវិស័យបរិស្ថាន

- បានសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍រួមមាន ADB និង AFD ដើម្បីអនុវត្តគម្រោងកែលម្អហេដ្ឋារចនាសម្ព័ន្ធខ្សែច្រវាក់តម្លៃកសិកម្ម Agricultural Value Chain Infrastructure Improvement Project-A VIP សម្រាប់អនុវត្តឆ្នាំ២០២១

- បានសម្របសម្រួលស្នើគម្រោងចំនួន ១៩ទៅស្ថានទូតជប៉ុន។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការងារអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៣០ក្រុមហ៊ុន សរុបចំនួន ២ ៥១៩មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២៣៧ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៨៤ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៧៤ក្រុមហ៊ុន

- ចេញលិខិតអនុញ្ញាតវេចខ្ចប់ជាថ្មីថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៩ក្រុមហ៊ុន។

**១៣.២ ការងារមន្ទីរពិសោធន៍**

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៨១ក្រុមហ៊ុន សរុបចំនួន ៥៧០សំណាក។

**១៣.៣ ការងារអភិវឌ្ឍបទដ្ឋានគតិយុត្ត**

- បានចុះធ្វើសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងបទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រងនិងការធ្វើអាជីវកម្មសម្ភារកសិកម្មនៅខេត្តកំពង់ចាម កំពង់ធំ និងខេត្តព្រៃវែង។

**១៣.៤ ការងារអនុវត្តច្បាប់**

- បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មខេត្តគោលដៅចំនួន ១៨ខេត្ត គឺ ខេត្តសៀមរាប បន្ទាយមានជ័យ ប៉ៃលិន បាត់ដំបង កណ្ដាល ឧត្ដរមានជ័យ ព្រះវិហារ តាកែវ មណ្ឌលគិរី រតនគិរី កំពង់ចាម កំពត កំពង់ធំ ព្រះសីហនុ កោះកុង ពោធិ៍សាត់ ក្រចេះ និងរាជធានីភ្នំពេញ ត្រួតពិនិត្យលើ ១៦ក្រុមហ៊ុន ៣ឃ្លាំងសន្និធិ ៩៧ដេប៉ូ និង ១មធ្យោបាយដឹកជញ្ជូន ដោយសម្រេចពិន័យអន្តរការណ៍សរុបចំនួន ២៨ករណី។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- បានបន្ថែមតំណភ្ជាប់លើគេហទំព័រក្រសួងដើម្បីទាញយកកម្មវិធីទូរស័ព្ទ (Mobile App) របស់ក្រសួងក្នុង Playstore និង Appstore

- ចុះបណ្ដុះបណ្ដាល តាមដានការប្រើប្រាស់ និងបង្ហាញមុខងារប្រើប្រាស់ថ្មីៗលើគេហទំព័ររបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន១០ ដូចជា៖ ខេត្តកំពង់ស្ពឺ សៀមរាប កំពង់ធំ កោះកុង តាកែវ ព្រះសីហនុ រតនគិរី មណ្ឌលគិរី ក្រចេះ និងខេត្តស្ទឹងត្រែង

- ចុះប្រមូលទីតាំងដំណាំស្រូវប្រាំងចំនួន០៣ខេត្ត គឺខេត្តស្វាយរៀង តាកែវ និងខេត្តព្រៃវែង ដោយបានប្រមូលយកទីតាំងដំណាំស្រូវប្រាំងចំនួន២០៤ចំណុច សម្រាប់ធ្វើការវិភាគកំណត់សម្គាល់តំបន់ស្រូវប្រាំង និងបរិមាណស្រូវប្រាំង

- បានសហការជាមួយរាជបណ្ឌិតសភាវិទ្យាសាស្ត្រនៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីសិក្សា និងប្រមូលទិន្នន័យសម្រាប់ប្រព័ន្ធតាមដានដំណាំ៣ប្រភេទ រួមមាន៖ ដំណាំស្រូវ ពោត និងដំណាំសណ្ដែក សម្រាប់ប្រទេសកម្ពុជា

- បន្តការធ្វើបច្ចុប្បន្នភាពលើគេហទំព័របណ្ណាល័យកសិកម្ម និងជំរុញការផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលការប្រើប្រាស់អំពីគេហទំព័របណ្ណាល័យកសិកម្ម និងពិនិត្យអំពីការរៀបចំបណ្ណាល័យរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន១០ គឺខេត្តព្រះវិហារ ក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ កណ្ដាល និងខេត្តព្រៃវែង

- បានតាមដានទិន្នន័យ និងសម្អាត Catch នៅលើ Cloud Server នៃគេហទំព័រទាំង៤១។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានចុះទៅថត Video បទយកការណ៍ចំនួន ២២ប្រធានបទ

- បានធ្វើការផលិត និងចាក់ផ្សាយឡើងវិញចំនួន ១២ប្រធានបទលើវេទិកាស្វែងយល់ពីកសិកម្ម

- បានផលិតឯកសារ Video នាទីចុះស្រែជាមួយកសិករចំនួន ១៣ប្រធានបទ

- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ៧២ដើម្បីចាក់ផ្សាយ

- បានជួយដោះស្រាយបញ្ហា និងផ្ដល់ព័ត៌មានបច្ចេកទេសកសិកម្មនានាដល់កសិករចំនួន ២៨៦សំណួរចម្លើយតាមបណ្ដា២៥រាជធានី-ខេត្ត

- បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពីផលិតកម្មដំណាំបន្លែ និងផលិតកម្មដំណាំស្រូវនៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាល និងផ្សព្វផ្សាយកសិកម្មតាស្អាងមានអ្នកចូលរួមចំនួន ១១៨នាក់។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- ពាក់ព័ន្ធការងារអនុវត្តកសិកម្មតាមកិច្ចសន្យា ក្រសួងរៀបចំឲ្យបង្កើតបានរួចហើយនូវអនុគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្មនៅថ្នាក់រាជធានី-ខេត្តបានចំនួន ២៥ទូទាំងប្រទេស និងបានរៀបចំរួចហើយនូវផែនការយុទ្ធសាស្ត្រកសិ-ឧស្សាហកម្មឆ្នាំ២០១៩-២០៣០

- សហគមន៍កសិកម្មចំនួន ២៩២សហគមន៍ ក្រុមកសិករ សហគមន៍ និងកសិករផ្សេងទៀតបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនធំៗចំនួន ៩៣៦កិច្ចសន្យា គឺ ប្រភេទផលិតផលសំខាន់ៗមានដូចជា ស្រូវចំនួន ១៨៦កិច្ចសន្យាក្នុងបរិមាណ ៨២ ១៩៧តោន ដំឡូងមីចំនួន ២៦កិច្ចសន្យាក្នុងបរិមាណ ៥៤ ២៧២,២៧តោន គ្រាប់ស្វាយចន្ទីចំនួន ៩កិច្ចសន្យាក្នុងបរិមាណ ១០៥តោន អង្ករចំនួន ១កិច្ចសន្យាក្នុងបរិមាណ ៣០១,១៩តោន ចុងអង្ករចំនួន ១កិច្ចសន្យាក្នុងបរិមាណ ១ ០៨០តោន ពោតចំនួន ៣កិច្ចសន្យាក្នុងបរិមាណ ៥០៨តោន ជ្រូកចំនួន ២៣៥កិច្ចសន្យាក្នុងបរិមាណ ៣៤ ៨៤៥តោន មាន់សាច់ចំនួន ២០៨កិច្ចសន្យាក្នុងបរិមាណ ២ ៧៦៨ ៨៩១ក្បាល មាន់ស្រែចំនួន ៥៨កិច្ចសន្យាក្នុងបរិមាណ ៧៣៩,៥៧តោន និង២៤១ ៣២៤ក្បាល គោចំនួន ៥កិច្ចសន្យាក្នុងបរិមាណ ១ ០៩៣ក្បាល កូនមាន់ស្រែចំនួន ២៤កិច្ចសន្យាក្នុងបរិមាណ ៧៦៩ ៤២០ក្បាល ពូជត្រីគ្រប់ប្រភេទចំនួន ១៥កិច្ចសន្យាក្នុងបរិមាណ ៩៤,៩០តោន និង៤ ៣២០ ០០០ក្បាល ស៊ុត-មាន់ស្រែចំនួន ១៣កិច្ចសន្យាក្នុងបរិមាណ ១ ៣២៧ ៥៥០គ្រាប់ ស៊ុតទាចំនួន ២កិច្ចសន្យាក្នុងបរិមាណ ១០០ ០០០គ្រាប់ បន្លែចំនួន ៦២កិច្ចសន្យាក្នុងបរិមាណ ១០ ៣០០,៤២តោន បន្លែផ្លែឈើចំនួន ១២កិច្ចសន្យាក្នុងបរិមាណ ១៩៣,៤១តោន ចេកចំនួន ២កិច្ចសន្យាក្នុងបរិមាណ ២២,២០តោន ឪឡឹកចំនួន ២កិច្ចសន្យាក្នុងបរិមាណ ២០៥,២០តោន ល្ពៅចំនួន ១កិច្ចសន្យាក្នុងបរិមាណ ២០,៥០តោន ជីធម្មជាតិចំនួន ១កិច្ចសន្យាក្នុងបរិមាណ ១ ០០០តោន ខ្ញីចំនួន ២កិច្ចសន្យាក្នុងបរិមាណ ២,០៨តោន ខ្ទឹមសចំនួន ២កិច្ចសន្យាក្នុងបរិមាណ ២តោន ម្សៅដំឡូងមីចំនួន ១កិច្ចសន្យាក្នុងបរិមាណ ៥០តោន ក្រូចឆ្មាចំនួន ១កិច្ចសន្យាក្នុងបរិមាណ ៩១,២៥តោន ទំពាំងផ្អែមចំនួន ២កិច្ចសន្យាក្នុងបរិមាណ ៣៨តោន ក្រូចពោធិ៍សាត់ចំនួន ១កិច្ចសន្យាក្នុងបរិមាណ ១ ៤០០តោន ក្រូចវល្លិចំនួន ១កិច្ចសន្យាក្នុងបរិមាណតាមតម្រូវការ អំពៅចំនួន ១កិច្ចសន្យាក្នុងបរិមាណ ៣៦,៥០តោន ទាកាប៉ាចំនួន ១កិច្ចសន្យាក្នុងបរិមាណ ៩៨,៥៥តោន ផលិតផលកែច្នៃចំនួន ១កិច្ចសន្យាក្នុងបរិមាណតាមតម្រូវការ ស្ករត្នោតចំនួន ១កិច្ចសន្យាក្នុងបរិមាណ ១៣០តោន និងផ្គត់ផ្គង់ធាតុចូលសម្ភារៈកសិកម្មចំនួន ៥០កិច្ចសន្យាក្នុងបរិមាណតាមតម្រូវការ

- បានកសាងគម្រោងវិភាគកាកសំណល់គីមី ថ្នាំកសិកម្ម លោហៈធ្ងន់ មីកូតុកស៊ីន និងសារធាតុពុលផ្សេងៗទៀតក្នុងផលិតកម្មកសិកម្ម និងចំណីអាហារ

- បានវិភាគរកសមាសធាតុគីមី លោហៈធ្ងន់ គុណភាព និងអាហារូបត្ថម្ភនៅក្នុងផលិតផលកសិកម្មម្សៅ អង្ករ ពោតលឿង ទឹកឃ្មុំ បន្លែស្រស់

- បានរៀបចំសេវាវិភាគគុណភាពសុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហាររួចហើយ កំពុងរង់ចាំការសម្រេចភ្ជាប់ជាឧបសម្ព័ន្ធក្នុងប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបន្តពង្រឹងសមត្ថភាពមន្ទីពិសោធន៍ដើម្បីអនុលោមភាពក្នុងកំរិតស្តង់ដារ១៧០២៥

- បាននិងកំពុងរៀបចំប្រមូលចងក្រងទិន្នន័យសិប្បកម្ម សហគ្រាសកសិឧស្សាហកម្មធុនតូចបំផុត តូច មធ្យម និងធំដើម្បីសិក្សា វិភាគនូវសមត្ថភាពផលិតកែច្នៃ តម្រូវការផលិតផលកសិកម្មជាវត្ថុធាតុដើមឆ្លើយតបតាមទាំងបរិមាណ និងគុណភាពដែលសហគ្រាសចង់បាន

- បណ្តុះបណ្តាល ផ្សព្វផ្សាយចំណេះដឹងការកែច្នៃផលិតផលកសិកម្មដើម្បីទទួលបានតម្លៃបន្ថែម និងរក្សាទុកបានយូរ

- បានចុះបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តត្បូងឃ្មុំ

- បានចុះបណ្តុះបណ្តាលកសិករស្តីពីការលើកកម្ពស់ស្តង់ដារ គុណភាព និងសុវត្ថិភាពនៃផលិតកម្មកសិកម្មនៅខេត្តសៀមរាប

- បានចុះសិក្សាពីសក្តានុពលដំណាំបន្លែផ្លែឈើ ជាពិសេសបន្លែសរីរាង្គ និងការវិភាគគុណភាពទឹកក្រោមដីសម្រាប់ប្រើប្រាស់ និងផ្សព្វផ្សាយពីផលប្រយោជន៍នៃការផលិតមានផែនការឆ្លើយតម្រូវការទីផ្សារតាមយន្តការកិច្ចសន្យាផលិតកម្មកសិកម្ម

- បានសហការជាមួយក្រុមហ៊ុន Top Planning Japan លើការសិក្សាខ្សែច្រវាក់ស្វាយចន្ទីលើខេត្តគោលដៅចំនួន ៤ខេត្ត គឺ ខេត្តកំពង់ធំ កំពង់ចាម សៀមរាប និងខេត្តព្រះវិហារ និងសិក្សាគម្រោងសាកល្បងជាមួយសិប្បកម្មកែច្នៃគ្រាប់ស្វាយចន្ទីជ័យសំបូរ ខេត្តកំពង់ធំ

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រថ្មីៗនៃការវិភាគគុណភាព សុវត្ថិភាពផលិតផលកសិកម្ម និងចំណីអាហារនៅមន្ទីរពិសោធន៍ផលិតផលកសិកម្ម និងចំណីអាហារកម្ពុជា

- បានចុះបណ្តុះបណ្តាលកសិករស្តីពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិនៅខេត្តកំពត និងខេត្តត្បូងឃ្មុំ។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានបន្តការអភិរក្សពូជដំណាំចំនួន ៣៨ប្រភេទ រួមមានស្រូវចំនួន ៦ ៧៧៦បញ្ជីក/សំណាក និងដំណាំផ្សេងៗ ចំនួន ៣៧ប្រភេទ សរុបចំនួន ២ ៤១១បញ្ជីក/សំណាក សរុបទាំងអស់មានចំនួន ៩ ១៨៧បញ្ជីក/សំណាក

- បានដាំវាយតម្លៃ និងកំណត់លក្ខណលើដំណាំពីរមុខគឺ ដំណាំល្ពៅចំនួន ១២សំណាក និងសណ្តែកព្រៃចំនួន ៥០សំណាក

- បានដាំវាយតម្លៃប្រភេទពូជម្ទេស និងត្រសក់ស្រូវដែលទើបប្រមូលចំនួន ៩០ពូជ និងរៀបចំសៀវភៅកាតាឡុកម្ទេសទី១ដោយបានបោះពុម្ពរួចរាល់

- បានធ្វើពិសោធន៍ចំនួន ១០៨ប្រភេទ នៅ៥៣០កន្លែងដែលនៅក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន ៣៦៩កន្លែង ធ្វើអង្កេតចំនួន ៤ប្រភេទលើកសិករចំនួន ៤ ៩០០នាក់ ធ្វើទិវាស្រែបង្ហាញចំនួន ១៥លើក មានកសិករចូលរួមចំនួន ៥២៣នាក់ (ស្រី២៧៦នាក់) និងបើកវគ្គបណ្តុះបណ្តាលកសិករចំនួន ២៦លើក មានកសិករចូលរួមចំនួន ១ ០៥១នាក់ (ស្រី៦៤៥នាក់)

- បានបើកវគ្គបណ្តុះបណ្តាលនៅវិទ្យាស្ថានបានចំនួន ២វគ្គដែលមានអ្នកចូលរួមសរុបចំនួន ៥៦នាក់ (ស្រី១៤នាក់) ដឹកនាំនិស្សិតចុះធ្វើកម្មសិក្សាសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រចំនួន ១១រូប (ស្រី៣រូប) មកពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យអន្តរជាតិ សាកលវិទ្យាល័យស្វាយរៀង និងវិទ្យាស្ថានសន្តប៉ូល

- បានចែកពូជស្រូវក្នុងចំណាត់ថ្នាក់ពូជស្រូវសុទ្ធល្អសរុបចំនួន ១ ៣៧៥គ.ក្រ ដល់កសិករសម្រាប់ការងារបង្កបង្កើនផលស្រូវក្នុងឆ្នាំ២០២០ ជាពូជស្រូវធានាបាននូវភាពសុទ្ធ និងទិន្នផលខ្ពស់

- បានបោះពុម្ពឯកសារឡើងវិញចំនួន ២៣ ៤២០ច្បាប់ និងបែងចែកឯកសារសរុបចំនួន ៩ ៥៥០ច្បាប់។ ចំនួនអ្នកប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យារបស់វិទ្យាស្ថានតាមរយៈគេហទំព័រ http://www.cardi.org.kh មានចំនួនសរុប ១ ៦៩៦ ២៧៧នាក់ ដោយគិតជាមធ្យមមានប្រមាណ ៥ ១៤០នាក់/ថ្ងៃ។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- បាននិងកំពុងដំណើរការបង្រៀននិស្សិតពីចំងាយតាមរយៈប្រព័ន្ធអេឡិចត្រូនិក និងតាមអនឡាញសម្រាប់កម្មវិធីសិក្សាឆមាសទី២ឆ្នាំសិក្សា២០១៩-២០២០ ដោយប្រទ្បងបញ្ចប់ឆមាសទី២នៅចុងខែវិច្ឆិកា។ ម៉្យាងទៀត គ្រប់មហាវិទ្យាល័យបានដំណើរការនៃការការពារសារណាបទបញ្ចប់ការសិក្សាឆ្នាំទី៤ ថ្នាក់បរិញ្ញា បានចប់រួចរាល់នៅចុងដំណាច់ខែវិច្ឆិកានេះ ហើយចាប់ផ្តើមបវេសនកាលឆ្នាំថ្មី នៅថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០២០ នេះផងដែរ

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប៉ាន់ប្រមាណប្រព័ន្ធនវានុវត្តន៍កសិកម្មក្នុងក្របខ័ណ្ឌគម្រោង ការអភិវឌ្ឍសមត្ថភាព និងស្ថាប័នក្នុងប្រព័ន្ធនវានុវត្តន៍កសិកម្មដែលទទួលបានការឧបត្ថម្ភថវិកាពីអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិប្រចាំកម្ពុជា (FAO)

- បានចុះធ្វើការសិក្សា និងវាយតម្លៃសក្តានុពលនៃប្រព័ន្ធជីវឧស្ម័ន ធ្វើបទបង្ហាញអំពីរបាយការណ៍វាយតម្លៃសង្ខេបអំពីគម្រោងសាងសង់ប្រព័ន្ធជីវឧស្ម័ន និងពិភាក្សាអំពីនីតិវិធីការគាំទ្រហិរញ្ញប្បទានក្នុងដំណាក់កាលដំបូងជូនម្ចាស់កសិដ្ឋានចិញ្ចឹមជ្រូកនៅក្នុងខេត្តកំពង់ធំ និងខេត្តព្រះសីហនុ និងសហការដឹកនាំចុះរៀបចំថតវីដេអូផ្សព្វផ្សាយមជ្ឈមណ្ឌលជាមួយកសិដ្ឋាន M's pig និងចុះពិនិត្យដំណើរការប្រព័ន្ធចម្រោះឧស្ម័ននៅក្នុងកសិដ្ឋាននោះតែម្តង។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៩-២០២០ សរុបចំនួន ៩៤៣នាក់ (ស្រី៣៨៧នាក់) លើជំនាញ៖ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស

- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការរៀបចំបង្កើត និងការបណ្តុះបាក់តេរីអ៊ីកូលីក្នុងលាមកបក្សី

- បានទៅស្ថានីយ៍ពិសោធន៍កសិកម្មរបស់វិទ្យាស្ថានចំនួន ២លើកដើម្បីពិនិត្យស្ថានភាពដំណាំ ដាំដំណាំពិសោធន៍ និងព្យាបាលជំងឺគោកើតអុតក្តាម

- បន្តការស្រាវជ្រាវលើ ផ្កាអ័រគីដេ ចេក ស្វាយចន្ទី ត្រី ជាដើម

- បានដំណើរការសាងសង់កសិដ្ឋានចិញ្ចឹមគោយកទឹកដោះនៅក្នុងវិទ្យាស្ថានជិតរួចរាល់។

**១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម**

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៩-២០២០ សរុបចំនួន ៦៥៦នាក់ (ស្រី២៨៦នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់

- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា

- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការពិសោធន៍លើការចិញ្ចឹមបង្កងពូជអូស្ត្រាលីចំនួន ១៦៥គូ និង២៥០កូន នៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការពិសោធន៍លើការចិញ្ចឹមសាកល្បងពូជកន្ធាយក្នុងស្រុកចំនួន ៦០០ក្បាលនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប

- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្ពៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច។

**១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា**

- បានអនុវត្ត និងបន្តការងារស្រាវជ្រាវ និងតាមដានទិន្នន័យចម្ការពិសោធន៍នៅក្នុងស្ថានីយ នៅតាមបណ្តាក្រុមហ៊ុនចម្ការកៅស៊ូសរុបចំនួន ៦២ពិសោធន៍

- បាញ់ថ្នាំការពារ និងព្យាបាលជំងឺផ្កាកុលាបនៅតាមប្រគៀបមែកកៅស៊ូចាប់ពីអាយុ៣-១០ឆ្នាំ

- តាមដានការស្រង់ និងបញ្ចូលទិន្នន័យចម្ការពិសោធន៍ក្នុងនិងក្រៅស្ថានីយចំនួន ១៧ចម្ការពិសោធន៍

- ចុះអង្កេតការជ្រុះស្លឹក និងចេញផ្កានៅច្បារបង្កាត់ពូជលើក្លូនកៅស៊ូចំនួន១៦

- វិភាគរកស្តង់ដាស់សរីរទឹកជ័រ LD លើប៉ារ៉ាម៉ែត្រ Inorganic Phosphorus, Sucrose និង Thiol

- យកសំណាក និងវិភាគ LD ចម្ការពិសោធន៍នានាក្នុង និងក្រៅស្ថានីយចំនួន២៩ចម្ការ ស្មើនឹង១ ២៨០សំណាក

- ធ្វើតេស្ត និងបានចេញលទ្ធផលតេស្តជូនរោងចក្រកៅស៊ូសន្លឹករបស់វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាចំនួន ៩ដង

- រៀបចំពិសោធន៍លើការប្រើប្រាស់អាស៊ីត៣ប្រភេទខុសគ្នាលើទឹកជ័រកៅស៊ូក្លូន GT1 និង PB217។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារប្រមូលផលស្រូវរដូវវស្សាសម្រេចបានចំនួន ២ ៥៩០ ៣៥២ហ.ត លើផ្ទៃដីអនុវត្តសរុបចំនួន ២ ៧៩០ ៨២៩ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៨ ២១៩ ៦៧៧តោន និងទទួលបានទិន្នផលគិតជាមធ្យម ៣,១៧៣តោន/ហ.ត។ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការ-ប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំ-កសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការដាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួត-ពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្ម

កសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មនៅក្នុងរដូវវស្សាឆ្នាំ២០២០ និងរដូវប្រាំងឆ្នាំ២០២១
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ
- ត្រៀមលក្ខណៈមានដូចជាៈ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល
- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូតិ៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

### ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង
- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន
- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត
- បន្តការតាមដានស្ថានភាពជំងឺស៊ូណូសជាប្រចាំនៅតាមបណ្តារាជធានី-ខេត្ត
- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)
- បន្តអនុវត្តការបង្កាត់ពូជគោ និងជ្រូកដោយសិប្បនិម្មិត។

### ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់
- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើឲ្យចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឲ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋាន ឲ្យយល់ដឹងពីផលប្រយោជន៍ព្រៃឈើ
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កច ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឲ្យបានជ្រួតជ្រាបដល់មូលដ្ឋាន ភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងឲ្យមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីរំលោភយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

**៤ ផ្នែកជលផល**

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្រ្កាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្រ្កាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

**៥ ផ្នែកពាក់ព័ន្ធផ្សេងៗ**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ៕

ថ្ងៃ សុក្រ ១០ កើត ខែ បុស្ស ឆ្នាំ ជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មករា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**